**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ១៤៦៧ ទសរ៧

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជម្រាបមក**
**លោក លន់ បូរិទ្ធី ប្រធានអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា**

**<u>កម្មវត្ថុ</u>** : អំពីការសុំចុះបញ្ជីរបស់ ***អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា*** ទៅក្រសួងមហាផ្ទៃ។

**<u>យោង</u>** : លិខិតលេខ*០២៨CCC២០១១* ចុះថ្ងៃទី*២៣* ខែ*សីហា* ឆ្នាំ*២០១១* ស្ដីពីការសុំចុះបញ្ជីរបស់***អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា*** ដែលមានអាសយដ្ឋានទីស្នាក់ការកណ្ដាលនៅផ្ទះលេខ*៩.១១* ផ្លូវលេខ*៤៧៦* សង្កាត់***ទួលទំពូងទី១*** ខណ្ឌ***ចំការមន*** ***រាជធានីភ្នំពេញ*** នោះហើយ ។***អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាអង្គការអព្យាក្រឹត មិនប្រកាន់ពូជ-សាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍តេររបក្សនយោបាយ ។

ក្រោយពីច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន អង្គការគណៈ-កម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីឱ្យបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន។
សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

នុត - សាអាន

<u>ចម្លងជូន :</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "<u>ដើម្បីជូនជ្រាប</u>"
- សាលារាជធានីភ្នំពេញ
  "<u>ដើម្បីអនុវត្ត</u>"
- ឯកសារ-កាលប្បវត្តិ

ទីស្ដីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh